# មេរៀនទី៩៖ ការរៀបចំការស្រាវជ្រាវ

Lesson 9: Research Design

**លទ្ធផលរំពឹងទុក មេរៀននេះ៖ បន្ទាប់ពីរៀនមេរៀននេះ គរុនិស្សិតនឹង**

- **ពន្យល់និយមន័យ និងមុខងារនៃការរៀបចំការស្រាវជ្រាវទាំងការស្រាវជ្រាវទូទៅ និងស្រាវជ្រាវប្រតិបត្តិ**

ការរៀបចំការស្រាវជ្រាវគឺជាផែនការលម្អិតដែល នឹងត្រូវប្រើដើម្បីតម្រង់ទិសការសិក្សាស្រាវជ្រាវឆ្ពោះទៅរកគោលដៅដែលអ្នកស្រាវជ្រាវត្រូវការ (Aaker et al., 2019)។ ការរៀបចំការស្រាវជ្រាវ ជាគម្រោង ជាផែនការ ជារចនាសម្ព័ន្ធ ជាយុទ្ធសាស្ត្រនៃការសង្កេតដើម្បី ឆ្លើយនឹងសំណួរស្រាវជ្រាវ ឬបញ្ហាស្រាវជ្រាវ (Kumar, 2011)។ ការរៀបចំការស្រាវជ្រាវ នឹងធ្វើឡើងដោយកំណត់ពីភាពច្បាស់លាស់ ពីប្រភេទនៃការស្រាវជ្រាវ ថាតើអ្នកសិក្សាស្រាវជ្រាវ នឹងជ្រើសរើសការស្រាវជ្រាវមួយណា រវាងការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ។

❖ **សំណួរសំខាន់ៗ នៃនីតិវិធី នៃការស្រាវជ្រាវ**
  - តើអ្វីដែលអ្នកនឹងត្រូវសិក្សាស្រាវជ្រាវ?
  - ហេតុអ្វីបានត្រូវសិក្សាវា?
  - តើមានទិន្នន័យប្រភេទអ្វីខ្លះដែលត្រូវការ?
  - តើកន្លែងណាដែលមានទិន្នន័យដែលត្រូវការ?
  - តើការសិក្សាត្រូវការពេលវេលាប៉ុន្មាន?
  - តើអ្វីដែលនឹងក្លាយជាសំណាកគំរូ?
  - តើបច្ចេកទេសប្រមូលទិន្នន័យអ្វីខ្លះដែលត្រូវប្រើ?
  - តើទិន្នន័យនឹងត្រូវវិភាគយ៉ាងដូចម្ដេច?

ការប្រៀបធៀបវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យអាចត្រូវបានពិនិត្យតាមជំហាននីមួយៗ ដូចខាងក្រោមនេះ៖




ក្រាម១.១ លំហូរនៃដំណើរការស្រាវជ្រាវ បែបបរិមាណវិស័យ និងគុណវិស័យ (Creswell, 2012)

- លក្ខណៈនៃការស្រាវជ្រាវបែបបរិមាណវិស័យ
  - ពណ៌នាអំពីបញ្ហាស្រាវជ្រាវ ដោយរៀបរាប់អំពីនិន្នាការ ឬតម្រូវការនៃការពន្យល់អំពីទំនាក់ទំនងរវាងអថេរ។
  - រៀបរាប់អំពីគោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ និងសម្មតិកម្មប្រកបដោយភាពជាក់លាក់ និង ច្បាស់លាស់ ហើយដែលអាចវាស់វែងនិងសង្កេតបាន។
  - បង្កើតកម្រងសំណួរដើម្បីប្រមូលទិន្នន័យ។
  - ប្រមូលទិន្នន័យជាលេខពីមនុស្សមួយចំនួនធំដោយប្រើឧបករណ៍និងកម្រងសំណួរដែលបានរៀបចំត្រៀម ទុកជាស្រេច។
  - វិភាគទិន្នន័យដើម្បីប្រៀបធៀបក្រុម ឬពិនិត្យទំនាក់ទំនងអថេរដោយប្រើវិធីសាស្ត្រស្ថិតិដើម្បីបកស្រាយ លទ្ធផល ហើយអាចប្រៀបធៀបលទ្ធផលទាំងនេះទៅនឹងការព្យាករណ៍ ឬការស្រាវជ្រាវមុនៗ។ និង
  - សរសេររបាយការណ៍ស្រាវជ្រាវដោយប្រើឃ្លោងឃ្លាឱ្យបានត្រឹមត្រូវច្បាស់លាស់ឱ្យស្របតាមគោលបំណង នៃការស្រាវជ្រាវព្រមទាំងមានតម្លៃនៃស្នាដៃស្រាវជ្រាវ និងប្រកបដោយក្រមសីលធម៌ត្រឹមត្រូវនៃវិជ្ជាជីវៈរបស់អ្នក សិក្សាស្រាវជ្រាវ។
    - **ការស្រាវជ្រាវបែបបែបពិសោធន៍ (Experimental) ឧ. ក្រុមសិស្សដែលគ្រូបង្រៀនបានប្រើវិធីសាស្ត្រIBL និងក្រុមសិស្សដែលគ្រូបង្រៀនប្រើវិធីសាស្ត្រប្រពៃណី**
    - **ការស្រាវជ្រាវបែបទំនាក់ទំនង (Correlational) ឧ. ទំនាក់ទំនងរវាងសិស្សពូកែមុខវិជ្ជារូបវិទ្យា និងគីមីវិទ្យា**
    - **ការស្រាវជ្រាវបែបពិពណ៌នា (Descriptive) ឧ. ស្ថានភាពសិក្សារបស់គរុនិស្សិត**

- លក្ខណៈនៃការស្រាវជ្រាវបែបគុណវិស័យ
  - ស្វែងយល់ពីបញ្ហានិងអភិវឌ្ឍការយល់ដឹងលម្អិតអំពីបាតុភូត និងរបកគំហើញថ្មីៗ។
  - ពិនិត្យឡើងវិញនូវទ្រឹស្តីនានាដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវ ឬបញ្ហាដែលត្រូវដោះស្រាយ ទោះជា មិនសូវមានសារសំខាន់ក៏ដោយ។
  - បញ្ជាក់គោលបំណងនិងសំណួរស្រាវជ្រាវជាទូទៅនិងទូលំទូលាយដែលទាក់ទងនឹងបទពិសោធន៍របស់ អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ។
  - ប្រមូលទិន្នន័យដោយផ្អែកលើពាក្យចេញពីមាត់បុគ្គលមួយចំនួនតូចដើម្បីធ្វើការសិទ្ធិដ្ឋានរួមនូវទស្សនៈ របស់អ្នកចូលរួមសិក្សាស្រាវជ្រាវ។
  - វិភាគទិន្នន័យបែបពិពណ៌នាដោយប្រើអត្ថបទវិភាគ និងបកស្រាយអត្ថន័យឱ្យបានសព្វជ្រុងជ្រោយ និង ស៊ីជម្រៅបំផុត។ និង

– សរសេររបាយការណ៍ដោយប្រើឃ្លោងឃ្លាឱ្យបានត្រឹមត្រូវច្បាស់លាស់ដែលអាចជឿទុកចិត្តបានដែល រំលេចនូវវិជ្ជាជីវៈនិងក្រមសីលធម៌របស់អ្នកស្រាវជ្រាវ។

  - ការស្រាវជ្រាវបែបករណីសិក្សា (Case study) ឧ. ករណីសិក្សា វិទ្យាល័យពេជ្រចិន្តា
  - ការស្រាវជ្រាវបែបជាតិពន្ធុសាស្ត្រ (Ethnography) ឧ. ជីវិតរស់នៅរបស់កម្មកររោងចក្រកាត់ដេរ
  - ការស្រាវជ្រាវបែបបាតុភូត (Phenomenology) ឧ. បទពិសោធន៍គ្រប់គ្រងរបស់នាយកសាលាវិទ្យាល័យ

❖ ការរៀបចំការស្រាវជ្រាវ

| ប្រភេទ | បែបបរិមាណវិស័យ | បែបគុណវិស័យ |
|---|---|---|
| លក្ខណៈពិសេស | ពណ៌នាពីប្រេកង់<br>មធ្យមនិងទំនាក់ទំនង<br>តេស្តសម្មតិកម្ម | ស្វែងយល់ពីបទពិសោធន៍<br>ជំនឿ និងគោលគំនិត |
| ប្រភេទការស្រាវជ្រាវ | ពិសោធន៍ Experimental<br>ទំនាក់ទំនងCorrelational<br>ពណ៌នា Descriptive | ករណីសិក្សា Case study<br>ជាតិពន្ធុសាស្ត្រ Ethnography<br>បាតុភូត Phenomenology |
| សំណាក | សំណាកគំរូ (Sampling) | សកលគំរូ (Key Informants) |
| ឧបករណ៍ស្រាវជ្រាវ | កម្រងសំណួរ, ទម្រង់អង្កេត, វិញ្ញាសាប្រឡង | សំណួរសម្ភាស, ទម្រង់អង្កេត |
| ការប្រមូលទិន្នន័យ | ស្ទង់មតិ, ការបំពេញទម្រង់សំណួរ, ប្រឡង... | សម្ភាសន៍, ពិភាក្សាក្រុម... |
| ការវិភាគទិន្នន័យ | Ms. Excel, SPSS... | ការវិភាគខ្លឹមសារ |
| លទ្ធផល | លទ្ធផលបែបស្ថិតិសន្និដ្ឋាន (Inferential Statistics)<br>លទ្ធផលបែបស្ថិតិពណ៌នា (Descriptive Statistics) | លទ្ធផលបែប ខ្លឹមសារ |

❖ គំរូទម្រង់ ការរៀបចំការស្រាវជ្រាវ

# ជំពូកទី ៣

# វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ........... មាននីតិវិធីនៃការស្រាវជ្រាវដូចទៅ៖

## ៣.១ រៀបវិធីស្រាវជ្រាវ (Research Design)

ការស្រវជ្រាវលើប្រធាននេះជាការស្រាវជ្រាវបែប .......... នៃគុណវិស័យ/បរិមាណវិស័យ/វិធីសាស្ត្រចម្រុះ... ដោយស្វែងយល់...

## ៣.២ ទីតាំង សកលគំរូ និងតំណាងគំរូ

ការស្រាវជ្រាវនេះបានធ្វើឡើងនៅ...... ដោយសារ..... និងប្រើប្រាស់បច្ចេកទេសជ្រើសរើសសំណាក....

## ៣.៣ ការប្រមូលទិន្នន័យ

ដើម្បីឆ្លើយតបនឹងកម្មវត្ថុនៃការស្រាវជ្រាវអំពី.........................

### ៣.៣.១. ឧបករណ៍ស្រាវជ្រាវ

..................................................

### ៣.៣.២. ដំណើរការប្រមូលទិន្នន័យ

................................................

## ៣.៤ ការវិភាគទិន្នន័យ

.........................................

## ៣.៥ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវយល់ច្បាស់ពីក្រមសីលធម៌ស្តីពីការស្រាវជ្រាវមានលិខិតចាត់តាំងពីវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ ដូចជាលិខិតឧទ្ទេសនាមដើម្បីចុះ

❖ **ក្រមសីលធម៌ នៃការស្រាវជ្រាវអប់រំ**

- ការយល់ព្រមដែលបានជូនដំណឹង
- ការលួចចម្លងស្នាដៃ
- ការបង្កើតទិន្នន័យ/ការបង្ហាញមិនពិត
- សម្ពាធលើការស្រាវជ្រាវ
- ការទទួលខុសត្រូវចំពោះសហគមន៍ស្រាវជ្រាវ
- មិនបង្កហានិភ័យដល់សំណាក
- រក្សាការសម្ងាត់
- សោះត្រង់ចំពោះទិន្នន័យ
- បង្ហាញប្រភពឯកសារយោង ... (Cohen et al., 2007)។